ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　　　　　ជាតិ　សាសនា　ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី　　　　　　　　　　៣៣៣*៣៣

លេខៈ ៣៩៩

ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤　　　　នាមនាមប្រជារាស្ត្រខ្មែរ

សាលដីកា　　　　　　　　　　　　តុលាការកំពូល

លេខៈ ២៨៧　　　　　　បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៦

ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៦　　ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឌិត** | **មុន្ទី** | ជាប្រធាន |
| ២-លោក | រៀល | មួន | ជាចៅក្រម |
| ៣-លោក | យស់ | សួខឿន | ជាចៅក្រម |
| ៤-លោក | សោម | សិរីវឌ្ឍ | ជាចៅក្រម |
| ៥-លោក | ម៉ុង | មុន្នីចរិយា | ជាចៅក្រម |

ក្រឡាបញ្ជី

លោកស្រី **អ៊ិន ឡាវី**

តំណាងមហាអយ្យការ

| | | | |
|---|---|---|---|
| ឯកឧត្តម | **ជួន** | **ស៊ុនឡេង** | ជាអគ្គព្រះរាជអាជ្ញារង |
| លោក | ជីវ | កេង | ជាចៅក្រមរបាយការណ៍"អវត្តមាន" |

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៥៤"យ"ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ២២៤ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍រាជធានី :

ដើមចោទឈ្មោះចិន **ស៊្រី** (ជាចុងបណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៦១ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះលេខ១៨៣ស្ទួន ផ្លូវ៣៦៩ ភូមិដើមចាន់ សង្កាត់ច្បារអំពៅ២ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។

មានមេធាវីលោក ឡុង ដារ៉ា .

ចុងចម្លើយឈ្មោះ **សោម ម៉ី** (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទស្រី អាយុ៧៥ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះលេខ១៨៣ ផ្លូវ៣៦៩ ភូមិដើមចាន់ សង្កាត់ច្បារអំពៅ២ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។

ផ្ទេរសិទ្ធិឱ្យឃឹម ម៉ុន និង ឃឹម សុខុម .

ចុងចម្លើយឈ្មោះ **ចាង អេង** (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទស្រី អាយុ៦៣ឆ្នាំ ជាតិខ្មែរ មុខរបរលក់គ្រឿងបន្លាស់ម៉ាស៊ីន មានទីលំនៅផ្ទះលេខ១៤៣ ផ្លូវ៣៦៩ ភូមិដើមចាន់ សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ ក្រុង ភ្នំពេញ ។

ផ្ទេរសិទ្ធិឱ្យឃឹម ម៉ុន និង ឃឹម សុខុម .

ចុងចម្លើយឈ្មោះ **ឃឹម ម៉ុន** (ជាម្ចាស់បណ្តឹងសាទុក្ខ) អាយុ៧៣ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ មានទីលំនៅផ្ទះលេខ១៤១ ផ្លូវ៣៦៩ ភូមិដើមចាន់ សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

មានមេធាវីលោកចាន់ សុខឃាង និង ម៉ម កែវស៊ីវិន .

**កម្មវត្ថុបណ្តឹង** : ប្តឹងទាមទារថ្លៃខូចខាតបណ្តាលមកពីអគ្គិភ័យ .

បានឃើញបណ្តឹងសាទុក្ខលេខ៣០៤ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៤របស់ឈ្មោះឃឹម ម៉ុន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៥៤"យ" ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញបណ្តឹងសាទុក្ខលេខ៣០៥ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៤របស់ឈ្មោះខួង ស្មើ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៥៤"យ" ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៩៩ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងរបស់ដើមចោទឈ្មោះប៊ិន ស្រ៊ី និងស្រ៊ី គីមលាង ប្តឹងទាមទារការខូចខាតពីចុងចំលើយឈ្មោះសោម រ៉េន ដោយសំអាងហេតុថា កាលពីថ្ងៃទី០៣-៦-២០០៣ វេលាម៉ោងប្រហែល៦ល្ងាច ក្នុងខណៈដែលចរន្តអគ្គិសនីត្រូវដាច់ កូនចៅនៃក្រុមគ្រួសារនេះ បានដុតទៀនទុកចោលនៅជាន់ទី១ នៃផ្ទះរបស់ខ្លួនរួចនាំគ្នាចុះមកអង្គុយលេងមកខាងក្រៅផ្ទះអស់ ។ បន្ទាប់មកទៀននោះក៏ដួលរួចឆេះរាលដាលរហូតឆេះផ្ទះខ្លួន និងផ្ទះអ្នកជិតខាងទៀតអស់រលីង ។

តាមពាក្យបណ្តឹងតបរបស់ឈ្មោះសោម រ៉េន ដែលមានឈ្មោះខួង ស្មើ ជាតំណាងបានប្តឹងទាមទារការខូចខាតពីឈ្មោះប៊ិន ស្រ៊ី វិញដែរ ដោយសំអាងហេតុថា កាលពីវេលាដូចខាងលើក្នុងខណៈដែលចរន្តអគ្គិសនីត្រូវដាច់ឈ្មោះប៊ិន ស្រ៊ី ក៏បានយកម៉ាស៊ីនភ្លើងតូចមួយទៅដាក់លើឡោតឿនៃផ្ទះរបស់ខ្លួន រួចបញ្ឆេះ ហើយក៏បណ្តាលឱ្យភ្លើងឆាបឆេះផ្ទះខ្លួន និងផ្ទះអ្នកជិតខាងអស់រលីង ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ២១"ច" ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងរបស់ឈ្មោះបិន ស្រ៊ី និងស្រ៊ី គីមលាង ចុះថ្ងៃទី០៩-៦-២០០៣ ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២-ទទួលពាក្យបណ្ដឹងរបស់ឈ្មោះហុង អេង.ឃឹម ម៉ុន និងសោម រ៉េន ចុះថ្ងៃទី០៩-៦-២០០៣ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែត្រូវបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

៣-ទទួលស្គាល់ការផ្ទេរសិទ្ធិពីឈ្មោះស្រ៊ី គីមលាង មក បិន ស្រ៊ី ទុកជាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៤-ទទួលស្គាល់ការផ្ទេរសិទ្ធិពីឈ្មោះឃឹម ម៉ុន.សោម រ៉េន.ហុង អេង មកឱ្យឈ្មោះខួង រស្មី ទុកជាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៥-បង្គាប់ឱ្យឈ្មោះសោម រ៉េន សងសំណងដល់ជនរងគ្រោះដូចតទៅ :

ក-បិន ស្រ៊ី ចំនួន ៥០០០$US (ប្រាំពាន់ដុល្លាអាមេរិក)

ខ-ស្រ៊ី គីមលាង ចំនួន ៤០០០$US (បួនពាន់ដុល្លាអាមេរិក)

សំណើលើសពីនេះត្រូវបដិសេធចោល ។

៦-ករណីគ្មានប្រាក់សង ឬពុំព្រមសងត្រូវរឹបអូសទ្រព្យសម្បត្តិឈ្មោះនេះលក់ឡាយឡុង ដើម្បីយកប្រាក់ធានាសំណងខាងលើ ។

៧-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន៧០០០៛ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្ពីង ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០០៛ ការចំណាយលើដីកាកោះ៥០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់៧០០០៛ ដែលដើមចោទបានបង់រួចជាស្រេច ។ កាលបើសាលក្រមចូលជាស្ថាពរ បង្គាប់ឱ្យឈ្មោះសោម រ៉េន បង់ប្រាក់ប្រដាប់ក្ដីចំនួន ៧០០០៛ ព្រមទាំងបង្គាប់ឱ្យឈ្មោះនេះសងប្រាក់៧០០០៛ ទៅដើមចោទវិញ និង ឱ្យបង់ពន្ធសមាមាត្រ១%នៃប្រាក់ដែលត្រូវសងដោយប្រាក់នេះបង់ចូលថវិការដ្ឋ៨០% និងសំរាប់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។

៨-សាលក្រមនេះបានជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខភាគីដើមចោទ និងភាគីចុងចំលើយ សំរេចបើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ១៣"ច"ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០៤ របស់ឈ្មោះខួង រស្មី ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ២១"ច"ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសេចក្ដីសំរេចទាំងមូល ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ១៤"ច"ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៤ របស់ឈ្មោះបិន ស្រ៊ី ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ២១"ច"ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៥៤"យ" ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០១-៤-២០០៤ របស់ឈ្មោះប៊ិន ស្រ៊ី និងស្រ៊ី គឹមលាង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០-៣-២០០៤ របស់ឈ្មោះខួង ស្មើ តំណាង ឱ្យឈ្មោះឃឹម ម៉ុន,សោម រ៉េន ,ហុង អេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយ ទាស់នឹងគតិច្បាប់ ។

៣-តំកល់សាលក្រមរដ្ឋប្បវេណីលេខ ២១"ច" ចុះថ្ងៃទី១០-០៣-២០០៤របស់ តុលាការក្រុងភ្នំពេញ វៀរលែងតែចំណុចទី៥ ដែលត្រូវកែប្រែជា :

ក-ប៊ិន ស្រ៊ី ចំនួន ៥០០០ដុល្លាអាមេរិក ទៅជា ៦១៤៧.២៥ដុល្លាអាមេរិក

ខ-ស្រ៊ី គឹមលាង ចំនួន ៤០០០ដុល្លាអាមេរិក ទៅជា៥២១៤.៣០ដុល្លាអាមេរិក.

ចំណុចផ្សេងទៀតរក្សាទុកជាបានការ ។ សំណូមពរលើសពីនេះបដិសេធចោល។

៤-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន២៦.០០០រ ។

៥-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៤-០៨-២០០៤ ចំពោះមុខ គូភាគី និងប្រកាសជាសាធារណៈនៅថ្ងៃទី៦-៨-២០០៤ ចំពោះមុខគូក្តី បើកផ្លូវសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣០៨ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៤របស់ឈ្មោះឃឹម ម៉ុន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៥៤"យ" ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញបណ្តឹងសាទុក្ខលេខ៣០៩ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៤របស់ឈ្មោះខួង ស្មើ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៥៤"យ" ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់ឈ្មោះឃឹម ម៉ុន ។

បានឃើញសារណាការពារ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៤ របស់ឈ្មោះខួង ស្មើ ។

បានឃើញសារណាឆ្លើយតប ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥ របស់ឈ្មោះប៊ិន ស្រ៊ី ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :បណ្តឹងសាទុក្ខរបស់ឈ្មោះខួងស្មើ តំណាងឱ្យសោម រ៉េន និងឈ្មោះហុង អេង និងបណ្តឹងសាទុក្ខរបស់ឈ្មោះឃឹម ម៉ុន ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិចារណា ។

សាលដីកាជួប្បវេណីលេខ ៩៤"យ"ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ ពុំត្រឹមត្រូវទេ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់។

បានស្តាប់ចម្លើយរបស់ឈ្មោះ យឹម សុខុម នាពេលសវនាការថា : រឿងនេះដើមហេតុគឺភ្លើងបានឆេះពីផ្ទះបិន ស្រ៊ី ដែលបណ្តាលមកពីគាត់បញ្ចេះម៉ាស៊ីនភ្លើង ឱ្យតែពេលដាច់ចរន្តអគ្គិសនីម្តងៗ គាត់តែងតែបញ្ចេះម៉ាស៊ីនភ្លើង ហើយនៅក្នុងផ្ទះរបស់គាត់ដាក់សុទ្ធតែម៉ាស៊ីនភ្លើង សល់តែច្រកដើរតូចមួយប៉ុណ្ណោះ ។

ការដែលឈ្មោះបិន ស្រ៊ី បញ្ចេះម៉ាស៊ីនភ្លើង គឺគាត់បញ្ចេះនៅលើឡៅតឿ ហើយឡៅតឿផ្ទះរបស់គាត់ធ្វើអំពីឈើលើ ថ្មក្រោម ជាប់នឹងឡៅតឿ របស់ខ្លួន ដូច្នេះបណ្តាលឱ្យងាយឆេះជាទីបំផុត ហើយនៅពេលភ្លើងកំពុងឆេះ មានគេស្រែកថា មានភ្លើងឆេះពីផ្ទះតាស្រ៊ី ខ្លួនក៏ក្រឡេកទៅឃើញភ្លើងឆេះចេញពីជញ្ជាំងផ្ទះរបស់ឈ្មោះបិន ស្រ៊ី ។

បានស្តាប់ចំលើយរបស់ឈ្មោះយឹម ម៉ុន នាពេលសវនាការថា : នៅល្ងាចថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៣ វេលាម៉ោង៦ល្ងាច មានគេស្រែកថា ភ្លើងឆេះផ្ទះតា ស្រ៊ី ពេលនោះខ្លួនរស់ចេញពីផ្ទះ ហើយខ្លួនឃើញភ្លើងឆេះផ្ទះ បិន ស្រ៊ី មុនផ្ទះសោម រ៉េន ហើយសង្កឹសផ្ទះ បិន ស្រ៊ី ហ៊ើងទៅលើផ្ទះសោម រ៉េន រយៈពេលតែ ៤៥នាទីឆេះអស់រលីង នៅតែផ្ទះខ្លួនឆេះក្រោយគេ នៅសល់ខ្លះ ។ ពេលកំពុងឆេះនៅក្នុងផ្ទះ បិន ស្រ៊ី មានឮសូរផ្ទុះ ។

សំណូមពរ : សុំឱ្យបិន ស្រ៊ី សងផ្ទះ និងសំភារៈខ្លួនវិញចំនួនជាទឹកប្រាក់៣០.០០០ដុល្លាអាមេរិក ។

បានស្តាប់ចំលើយរបស់ឈ្មោះហុង អេង នាពេលសវនាការថា : ភ្លើងឆេះប្រហែលជាម៉ោង៦ល្ងាច កូនខ្លួនស្រែកថា ភ្លើងឆេះពីផ្ទះ តា ស្រ៊ី ពេលបានឮដូច្នេះខ្លួនបានរត់ចេញមកក្រៅ ហើយទៅអើតតាមប្រហោងផ្ទះតាស្រ៊ី ឃើញភ្លើងកំពុងឆេះក្នុងផ្ទះតា ស្រ៊ី យ៉ាងសន្ធោសន្ធៅមែន មួយសន្ទុះក្រោយមក ក៏ឆេះបន្តទៅផ្ទះកូនគាត់ ហើយបន្តទៅផ្ទះផ្សេងៗទៀត ។

សំណូមពរ : ឱ្យឈ្មោះបិន ស្រ៊ី សងប្រាក់ដើម្បីបានធ្វើផ្ទះវិញផង ។

បានស្តាប់ចំលើយរបស់ឈ្មោះបិន ស្រ៊ី នាពេលសវនាការថា : នៅថ្ងៃទី០៣-៦-២០០៣ វេលាម៉ោងប្រហែលជាង៦ល្ងាច មានភ្លើងឆេះមែន ហើយពេលនោះមានក្មេងស្រែកថា មានភ្លើងឆេះពីផ្ទះមីងពៅឯងហើយ ឈ្មោះមីងពៅ នោះគឺជាកូនរបស់ឈ្មោះសោម រ៉េន ខ្លួននឹងកម្មករម្នាក់បានឃើញភ្លើងឆេះពីខាងក្រោយផ្ទះសោម រ៉េន ពេលនោះខ្លួនពីនាក់កម្មករបានយកបំពង់ពន្លត់អគ្គិភ័យ ទៅជួយពន្លត់អស់បីបំពង់ ព្រមទាំងផងទឹកជះថែមទៀត ប៉ុន្តែមិនរលត់ទេ ។ នៅថ្ងៃនោះពេលភ្លើងអគ្គិសនីរលត់នៅផ្ទះសោម រ៉េន មានដុតទៀនបំភ្លឺមុខផ្ទះមួយដើម និងក្រោយផ្ទះ១ដើម តាមខ្លួនដឹងនៅក្នុងផ្ទះសោម រ៉េន មានខោអាវ និងឥវ៉ាន់ច្រើន ដែលងាយនឹងធ្វើឱ្យឆាបឆេះ នៅ

ពេលដែលគាត់មានការធ្វេសប្រហែស ដូចនេះខ្លួនសន្និដ្ឋានថា ការធ្វេសប្រហែសរបស់គាត់បានធ្វើឱ្យទៀនដួលឆេះសំភារៈដែលបណ្តាលឱ្យភ្លើងឆេះ ។

ហើយរឿងចោទប្រកាន់ថា ខ្លួនបញ្ឆេះម៉ាស៊ីនភ្លើងលើឡោតឿ គឺមិនពិតទេ ផ្ទះខ្លួននៅជាន់ផ្ទាល់ដី អាចបញ្ឆេះម៉ាស៊ីនលើដីបាន បើបញ្ឆេះលើឡោតឿ ខ្លួនមិនអាចដេកនៅទីនោះបានទេ បើសិនបណ្តាលមកពីម៉ាស៊ីន និងសាំងនោះ ម្ល៉េះសមកម្មកររលាកភ្លើងបាត់ទៅហើយ ។ ដូច្នេះចំលើយរបស់ឈ្មោះយឹម សុខុម ប្រឌិត មួលបង្កាច់ខ្លួនទាំងស្រុង ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកចាន់ សុខឃាង ជាមេធាវីការពារឱ្យចុងចំលើយបានលើកឡើងថា : តាមការស៊ើបអង្កេតសាកសួរសាក្សីមួយចំនួនដែលនៅក្នុងព្រឹត្តហេតុនោះ និងរបាយការណ៍របស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ក៏បានបញ្ជាក់ផងដែរថា ភ្លើងឆេះចេញពីផ្ទះ ប៊ិន ស្រ៊ី ហើយមិនតែប៉ុណ្ណោះក៏មានអ្នកសារពត៌មានកម្ពុជាថ្មី បានថតយករូបភាពពេលភ្លើងកំពុងឆេះចេញពីផ្ទះ ប៊ិន ស្រ៊ី យ៉ាងច្បាស់ថែមទៀតផង ។

សំណូមពរ : សុំឯកឧត្តមប្រធាន មេត្តាបដិសេធចោលសាលដីកាសាលាឧទ្ធរណ៍លេខ ៥៤ "យ" ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៤ ទាំងមូលដោយក្តីអនុគ្រោះ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកម៉ម កែវស៊ីរិន ជាមេធាវីការពារឱ្យចុងចំលើយ បានលើកឡើងថា : សុំឱ្យតុលាការកំពូលបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ដើម្បីធ្វើការជំនុំជំរះសារជាថ្មីឡើងវិញ ព្រោះថា សាលាឧទ្ធរណ៍បានធ្វើការកែប្រែចំណុចទី៥ ពីទឹកប្រាក់ចំនួនតិចឱ្យទៅច្រើន ។

សុំបដិសេធសាលដីកាលេខ ៥៤ "យ" ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៤ ទុកជាមោឃៈចាប់ពីពេលនេះតទៅ និងសុំឱ្យជនល្មើសងផ្ទះ និងសុំឱ្យតុលាការកំពូលមេត្តាពិចារណាប្រគល់ទៅដោយគតិយុត្តិធម៌ និងគតិច្បាប់ជាទីបំផុត ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកឡុង ដារ៉ា ជាមេធាវីការពារឱ្យដើមចោទ បានលើកឡើងថា :ប្រភពនៃការភ្លើងឆេះដែលភាគីចុងចំលើយទាំងអស់ឆ្លើយ ភ្លើងឆេះចេញពីផ្ទះ ប៊ិន ស្រ៊ី ដែលបណ្តាលមកពីបញ្ឆេះម៉ាស៊ីនភ្លើងនៅលើឡោតឿនោះ មិនសមហេតុសមផលទេ ពីព្រោះនៅផ្ទះ សោម រ៉េន ពេលចរន្តអគ្គិសនីដាច់ ក៏បានដុតទៀនបំភ្លឺផងដែរ ដោយអ្នកលក់ទៀន និងអ្នកទិញទៀនក៏បានបញ្ជាក់ផងដែរ ដូច្នេះការដុតទៀន បើយើងធ្វេសប្រហែសក៏អាចបណ្តាលឱ្យភ្លើងឆាបឆេះបានក្នុងពេលនោះដែរ ។

ដូច្នេះខ្លួនសុំសំណូមពរយ៉ាងទទូច សូមឱ្យឯកឧត្តមមេត្តាតំកល់សាលដីការដ្ឋប្បវេណីលេខ ៥៤ "យ" ចុះថ្ងៃទី០៦-០៨-២០០៤ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងស្រុងតាមច្បាប់។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីនៃគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣០៤ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៤ របស់លោកឃឹម ម៉ុន និងលេខ ៣០៥ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៤ របស់អ្នកស្រីខួង រស្មី តំណាងឱ្យអ្នកស្រីសោម រ៉េន និងអ្នកស្រី ហុង អេង ស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ ក៏ដូចជាតុលាការក្រុងភ្នំពេញដែរ ដែលសំរេចឱ្យអ្នកស្រីសោម រ៉េន ជាចុងចំលើយ សងការខូចខាតទៅដើមចោទទាំងពីរនាក់ ដោយសំអាងថាអគ្គីភ័យបានផ្តើមចេញពីផ្ទះរបស់អ្នកស្រីសោម រ៉េន នោះ ពុំទាន់មានសំអាងហេតុច្បាស់លាស់នៅឡើយទេ ពីព្រោះថា សំអាងរបស់គូភាគីមានលក្ខណៈប្រហាក់ប្រហែលគ្នា ដោយមានសាក្សីដែលបានឆ្លើយផ្តល់ផលប្រយោជន៍សំរាប់បណ្តឹងរៀង១ខ្លួន រីឯការបំភ្លឺរបស់មន្ត្រីជំនាញខាងអគ្គីភ័យក៏មានការប្រែប្រួលដែរ ដោយពីដំបូងថា អគ្គីភ័យកើតចេញពីផ្ទះរបស់ដើមចោទ តែក្រោយមកបានបដិសេធការបញ្ជាក់របស់ពួកគេវិញ ម្យ៉ាងទៀតសាលាឧទ្ធរណ៍មិនទាន់បានពិចារណាលើការបំភ្លឺ និងរូបថតរបស់សាក្សីឈ្មោះ ជ័យ មករា ដែលបានទៅដល់ទីតាំងកើតហេតុភ្លាម១នោះផងទេ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៩៤"យ"ចុះថ្ងៃទី០៦ខែសីហាឆ្នាំ២០០៤របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទំរង់និងទាំងគតិច្បាប់ហើយ។

## ហេតុដូចនេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៣០៤ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៤ របស់ លោកឃឹម ម៉ុន និងលេខ ៣០៥ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៤ របស់អ្នកស្រីខួង រស្មី តំណាងឱ្យអ្នកស្រី សោម រ៉េន និងអ្នកស្រីហុង អេង ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៩៤"យ"ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៣៩៩ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-របអូសប្រាក់ប្រដាប់ក្ដីដែលអ្នកស្រីហុង អេង និងលោកឃឹម ម៉ុន បានបង់ទុកនៅកុលាការកំពូលចំនួន ៣៨.០០០រ គឺ

-ពន្ធចុះបញ្ជីក្ដី នឹងពន្ធហ្មឹងចំនួន៤.០០០រ ប៉ុន្ដែប្រាក់នេះត្រូវកាត់ចំនួន ៨០០រ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រ សរុប១៩.០០០រ ។

នៅសល់ចំនួន១៩០០០រទៀត ត្រូវបង្វិលឱ្យអ្នកស្រីហុង អេង និងលោកឃឹម ម៉ុន ម្នាក់ពាក់កណ្ដាលវិញ និងតម្រូវឱ្យដើមចោទសងប្រាក់ចំនួន១៩.០០០រ ទៅចុងចំលើយវិញ ។

៥-សាលដីកានេះជំនុំជំរះនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៦ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៦ ។